ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃ សៅរ៍ ០៦រោច ខែ មិគសិរ ឆ្នាំ រកា ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី ០៩ ខែ ធ្នូ គ.ស.២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៧ អនក្រ.បក ចុះថ្ងៃ ចន្ទ ០៨ កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១៧ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

www.pheakdeylaw.com

សម្រេច

មាត្រា១._

ត្រូវបានអនុញ្ញាតឱ្យធ្វើនិយ័តកម្មឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ ជូនអាជ្ញាធរអប្សរា, អាជ្ញាធរជាតិព្រះវិហារ, សាលាខេត្តសៀមរាប, ក្រសួងទេសចរណ៍, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, និងអគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម÷

ឯកតា÷ ពាន់រៀល

ជំពូក	បរិយាយ	ច្បាប់ហិរ. ឆ្នាំ ២០១៨	ឥណទានមុននិយ័តកម្ម	និយ័តកម្ម		ឥណទានថ្មីក្រោយនិយ័តកម្ម
				កើន	ថយ	
	និយ័តកម្មចេញ				**49.616.000**	
	៩៩-ចំណាយមិនទាន់បែងចែកមានមុខសញ្ញា				**49.616.000**	
69	ចំណាយមិនបានគ្រោងទុក	676.504.000	597.310.000	-	49.616.000	547.694.000
	និយ័តកម្មចូល			**49.616.000**		
	០៧.១-ក្រសួងមហាផ្ទៃ-សន្តិសុខសាធារណៈ (អគ្គស្នងការនគរបាលជាតិ)			**1.230.200**		
62	អត្ថប្រយោជន៍សង្គម (អង្គភាពនគរបាលទេសចរណ៍)	11.116.000	11.116.000	1.230.200	-	12.346.200
	១០-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ			**5.300.000**		
65	ឧបត្ថម្ភធន (សាលាខេត្តសៀមរាប)	36.175.000	774.045.000	5.300.000	-	779.345.000
	១៨-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ			**40.645.800**		
62	អត្ថប្រយោជន៍សង្គម	3.138.000	3.138.000	2.260.000	-	5.398.000
65	ឧបត្ថម្ភធន	100.467.300	100.467.300	38.385.800	-	138.853.100
	-អាជ្ញាធរអប្សរា			32.746.800		
	-អាជ្ញាធរជាតិព្រះវិហារ			5.639.000		
	២៧-ក្រសួងទេសចរណ៍			**2.440.000**		
62	អត្ថប្រយោជន៍សង្គម	2.035.000	2.035.000	2.440.000	-	4.475.000

មាត្រា២._

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

www.pheakdeylaw.com

មាត្រា៣._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៥ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com